**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ១៤៧/២៣ អអរ

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តរតនគិរី"

នាព្រឹកថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តរតនគិរី»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ញ៉ែម សំអឿន អភិបាលនៃគណៈអភិបាលខេត្តរតនគិរី**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តរតនគិរី**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តរតនគិរី ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តរតនគិរី ស្ថិតនៅភាគឦសាន្ត នៃព្រះរាជាណាចក្រកម្ពុជា បែងចែកចេញជា ០១ក្រុង ៨ស្រុក ៥៦ឃុំ ៤សង្កាត់ និង២៤៣ភូមិ ដែលមានប្រជាជនសរុប ២២៧.២២៧នាក់ ស្មើនឹង ៥៣.៥៨៨គ្រួសារ ក្នុងនោះ មានជនជាតិដើមភាគតិចមាន ៨អម្បូរ ស្មើ ៥៦,៨៦% នៃប្រជាពលរដ្ឋសរុប។ សេដ្ឋកិច្ចខេត្តមានទំហំប្រមាណ ២៧០លានដុល្លារ ស្មើនឹង ១% នៃសេដ្ឋកិច្ចជាតិ ដែលប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗមានចំនួន ១.៣៦៧ដុល្លារអាមេរិក ក្នុងនោះ ប្រជាពលរដ្ឋប្រកបមុខរបរកសិកម្ម៨២,៤% សិប្បកម្ម០,៧% និងសេវាកម្ម១៦,៩%។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ ងាយរងគ្រោះ និងស្លាប់ដោយសារជំងឺកូវីដ-១៩ រួមទាំងស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ, ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យដោយសារសម្ពាធអតិផរណា និងគ្រួសារពិការភាព សរុបចំនួនថវិកា ៩១.៩៦១.១១១.៦០០រៀល។
- **វិស័យកសិកម្ម៖** ជាវិស័យអាទិភាពក្នុងការលើកកម្ពស់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ។ ខេត្តមានសក្តានុពលទៅលើដំណាំកសិកម្ម ដំណាំកសិ-ឧស្សាហកម្ម និងដំណាំរួមផ្សំមួយចំនួនទៀត ដោយក្នុងឆ្នាំ២០២២ បរិមាណផលស្រូវទទួលបានគឺ ៧៦.៣៤២តោន ស្វាយចន្ទី ៧៦.៥៦៤តោន កៅស៊ូ ៥១.១២៤តោន ដំឡូងមី ៤៣៨.៤៩៤តោន។ ជាមួយគ្នានេះ ខេត្តមានរោងចក្រកែច្នៃកៅស៊ូចំនួន ៧កន្លែង និងរោងចក្រកែច្នៃដំឡូងមីចំនួន ១កន្លែង។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ដោយមានការរួមសហការគ្នាពីថ្នាក់ដឹកនាំគណៈបញ្ជាការឯកភាពខេត្ត ប្រជាការពារ និងប្រជាពលរដ្ឋទាំងអស់ ទូទាំងខេត្តរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈបានយ៉ាងល្អប្រសើរ បទល្មើសគ្រប់ប្រភេទមានការថយចុះ។ ជាមួយគ្នានេះ ការអនុវត្តនូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ទទួលបានលទ្ធផលល្អប្រសើរ។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានខិតខំអភិវឌ្ឍន៍ ដោយធ្វើការសាងសង់ ជួសជុល ថែទាំជាបន្តបន្ទាប់ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់តភ្ជាប់ពីទីរួមខេត្ត ទៅកាន់គ្រប់បណ្តាភូមិទាំងអស់ សំដៅលើកកម្ពស់កិច្ចធ្វើដំណើររបស់ប្រជាពលរដ្ឋ ក្នុងការប្រកបរបរអាជីវកម្ម ដឹកជញ្ជូនទំនិញ និងបង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្ស ដើម្បីទទួលបានការអប់រំនៅតាមតំបន់ដាច់ស្រយាល ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ផងដែរ។ ជាមួយគ្នានេះ ខេត្តបានជំរុញនូវការលើកស្ទួយការងារអភិវឌ្ឍន៍ជនបទ ដោយបានពង្រីកនូវការផ្គត់ផ្គង់ទឹកស្អាតបានចំនួន ៧១,៧៦% និងអគ្គិសនីចំនួន ១២៦ភូមិ ស្មើនឹង ៥១,៩%។
- **វិស័យទេសចរណ៍៖** ដោយសម្បូរទៅដោយធនធានធម្មជាតិ ដែលជាសក្តានុពលអំណោយផលក្នុងការងារទេសចរណ៍ ក្នុងនោះវិស័យនេះក៏បានចូលរួមលើកស្ទួយសេដ្ឋកិច្ចខេត្តផងដែរ។ ក្នុងឆ្នាំ២០២២ ភ្ញៀវទេសចរមកទស្សនាក្នុងខេត្ត មានការកើនឡើងគួរកត់សម្គាល់ មានចំនួន ២៩៣.៤២៤នាក់ កើនឡើង១៤១,៥% បើធៀបនឹងឆ្នាំ២០២១។ ក្នុងការជំរុញនូវការងារទេសចរណ៍នេះ រដ្ឋបាលខេត្តបានបើកវគ្គបណ្តុះបណ្តាល ក៏ដូចជាសិក្ខាសាលាផ្សព្វផ្សាយទៅ

លើជំនាញវិជ្ជាជីវៈទេសចរណ៍ដល់ប្រជាពលរដ្ឋដូចជា ជំនាញគេហកិច្ច ជំនាញម្ហូបអាហារ ភេសជ្ជៈ មគ្គុទ្ទេសន៍ទេសចរណ៍ជាដើម ក្នុងន័យពង្រឹងការផ្តល់សេវាជូនភ្ញៀវ ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់ ទាក់ទាញបាននូវកំណើនភ្ញៀវទេសចរបន្ថែម។

- **វិស័យអប់រំ៖** រដ្ឋបាលខេត្ត បានខិតខំអនុវត្តកម្មវិធីកំណែទម្រង់នានា សំដៅលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ដោយក្នុងឆ្នាំ២០២២ ទូទាំងខេត្ត មានសាលាមត្តេយ្យសិក្សាសហគមន៍ និងរដ្ឋ សរុបចំនួន ១៨៨សាលា និងគ្រឹះស្ថាន សិក្សាសាធារណរដ្ឋ សរុបចំនួន ២៨៩សាលា មានសិស្សសរុបចំនួន ៥៩.៣៥៣នាក់ អត្រាសិស្សមធ្យមសិក្សាទុតិយភូមិបានប្រឡងជាប់ចន្លោះពី ៦៧% ទៅ ៩០%។
- **គម្រោងអភិវឌ្ឍន៍ខេត្ត៖** គម្រោងវិនិយោគស្នើឡើងដោយរដ្ឋបាលខេត្ត សរុបចំនួន ១.២៨៣ គម្រោង តម្លៃថវិកាចំនួន ៨៤៧.៩១៨.៤២០ពាន់រៀល ស្ថាប័ន-អង្គភាពគាំទ្រគម្រោងក្នុងវេទិកាពិគ្រោះយោបល់ចំនួន ៦៦៣ គម្រោង អនុវត្តសម្រេចបានចំនួន ៣៧០គម្រោង ស្មើនឹងថវិកា ៧៦.១៨៣.៥២០ពាន់រៀល ស្មើនឹង ៧៣,៩០%។ គម្រោងស្នើឡើងដោយរដ្ឋបាលឃុំ-សង្កាត់សរុបចំនួន ១២.៧១១គម្រោង តម្លៃថវិកាចំនួន ៤១៥.០៨៧.១៨០ពាន់រៀល ស្ថាប័ន-អង្គភាពគាំទ្រគម្រោងក្នុងសិក្ខាសាលាសមាហរណកម្មមានចំនួន ៤.៨២៣គម្រោង អនុវត្តសម្រេចបានចំនួន ៣.២៤៧គម្រោង ស្មើថវិកាចំនួន ៧៦.១៨៣.៥២០ពាន់រៀល ស្មើនឹង ៧៣,៩០%។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានប្តេជ្ញាបន្តខិតខំអនុវត្តកម្មវិធីនយោបាយនានា ជាពិសេសគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែទទួលបាននូវជោគជ័យបន្ថែម និងបន្តបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ សំដៅលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការអភិវឌ្ឍលើគ្រប់វិស័យ។ បន្តពង្រឹង និងអភិវឌ្ឍន៍ធនធានមនុស្ស គុណភាពអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ខិតខំអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គ្រប់ប្រភេទទាំងផ្លូវទីប្រជុំជន និងផ្លូវជនបទ ជំរុញនូវការផ្គត់ផ្គង់បណ្តាញទឹកស្អាត និងអគ្គិសនីឱ្យបានគ្រប់បណ្តាភូមិទាំងអស់។ បន្តជំរុញនូវការអប់រំ បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ក្នុងន័យលើកកម្ពស់ការងារកសិកម្ម ឱ្យកាន់តែទទួលបានទិន្នផលខ្ពស់។

ថ្ងៃអង្គារ ១៤កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣